TWR WOMEN OF HOPE

# ស្រ្តីក្នុងក្តីសង្ឃឹម
## ប្រតិទិនសំណូមអធិស្ឋាន

2025년 10월

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់



### ការអធិស្ឋានអំពីការរំលោភបំពានលើស្រ្តី

យោងតាមអង្គការសុខភាពពិភពលោក ស្រ្តីម្នាក់ក្នុងចំណោមស្រ្តីបីនាក់នៅទូទាំងពិភពលោកបានទទួលរងនូវអំពើហិង្សាផ្នែករាងកាយ ផ្លូវចិត្ត និង សេដ្ឋកិច្ច ពេញមួយជីវិតរបស់ពួកគេ។ អំពើហិង្សាក្នុងគ្រួសារមានភាគរយខ្ពស់បំផុត រីឯអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត (cyber violence) និង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ជាបញ្ហាធ្ងន់ធ្ងរផងដែរ។ នៅក្នុងទ្វីបអាហ្វ្រិកតែឯង ជាង២៣០លាននាក់នៃក្មេងស្រី និង ស្រ្តីបានទទួលរងនូវការកាត់ប្រដាប់ភេទស្រ្តី (FGM)។ ចូរចាក់ចេញនូវដួងចិត្តដែលឈឺចាប់ និង ព្រលឹងដែលនឿយហត់របស់បងប្អូននៅចំពោះព្រះអម្ចាស់ចុះ។ សូមឲ្យសេចក្តីសុខសាន្ត កម្លាំងថ្មី និង ក្តីសង្ឃឹមដែលព្រះអម្ចាស់ប្រទានមកសណ្ឋិតលើយើង ហើយស្តារយើងឡើងវិញ អាចឲ្យយើងថែមទាំងអត់ទោសដល់អ្នកដែលបានធ្វើបាបយើងបានទៀតផង។ ព្រះជាម្ចាស់ដែលបានបង្កើតយើង ទ្រង់មានព្រះហឫទ័យចង់ឲ្យយើងចងចាំថា យើងជាកូនជាទីស្រឡាញ់របស់ទ្រង់ ហើយទ្រង់អញ្ជើញយើងឲ្យមកឯទ្រង់ ដើម្បីស្វែងរកការសម្រាកពិតប្រាកដ។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면 매주 월요일에 기도카드를 받으실 수 있습니다.

1. ឱព្រះអម្ចាស់អើយ យើងសូមសរសើរតម្កើងព្រះអង្គសម្រាប់ស្រ្តីដែលត្រូវគេរំលោភបំពានបានស្គាល់ព្រះគ្រីស្ទតាមរយៈក្រុមការងារ Albanian របស់យើង ហើយឥឡូវនេះបានក្លាយជាអ្នកនាំមកនូវការផ្លាស់ប្តូរ ដើម្បីជួយស្រ្តីដទៃទៀតដែលកំពុងរងទុក្ខ! (ទំនុកដំកើង ១៨:៤៨)

2. ឱព្រះអម្ចាស់អើយ យើងសូមសរសើរតម្កើងព្រះអង្គសម្រាប់ស្រ្តីដែលត្រូវគេរំលោភបំពានបានស្គាល់ព្រះគ្រីស្ទតាមរយៈក្រុមការងារ Albanian របស់យើង ហើយឥឡូវនេះបានក្លាយជាអ្នកនាំមកនូវការផ្លាស់ប្តូរ ដើម្បីជួយស្រ្តីដទៃទៀតដែលកំពុងរងទុក្ខ! (ទំនុកដំកើង ១៨:៤៨)

3. ឱព្រះជាម្ចាស់អើយ សូមព្រះអង្គរំដោះម្តាយ និង កូនប្រុសជំទង់របស់នាងដែលរស់នៅក្នុងការភ័យខ្លាចចំពោះការរំលោភបំពានពីប្តី និង ឪពុកដែលញៀនថ្នាំរបស់ពួកគេនៅ អាស៊ីកណ្តាល។ (សុភាសិត ២៩:២៥)

4. ករណីជាច្រើននៃក្មេងស្រីរងការរំលោភបំពានផ្លូវភេទនៅក្នុងប្រទេសចិន នៅតែមិនត្រូវបានរាយការណ៍។ ឱព្រះអម្ចាស់អើយ សូមព្រះអង្គអន្តរាគមន៍ នាំមកនូវសុវត្ថិភាព ការស្តារឡើងវិញ និង ការព្យាបាល។ (ទំនុកដំកើង ១០:១៧–១៨)

5. ឱព្រះវរបិតាអើយ ស្រ្តីជាច្រើនត្រូវបានល្បួងដោយការសន្យាក្លែងក្លាយទៅកាន់ភាគខាងជើងនៃប្រទេស Cyprus ហើយលិខិតឆ្លងដែនរបស់ពួកគេត្រូវបានរឹបអូសទុក និង ត្រូវបានបង្ខំឲ្យធ្វើជាពេស្យាចារ។ សូមព្រះអង្គរំដោះពួកគេទាំងរូបកាយ និង ព្រលឹងវិញ្ញាណ។ (អេសាយ ៦១:១)

6. ឱព្រះជាម្ចាស់អើយ សូមព្រះអង្គរំដោះស្រ្តីនៅក្នុងប្រទេសដាណឺម៉ាក ដែលរងការរំលោភបំពានតាមរយៈអំពើហិង្សាក្នុងគ្រួសារ ឬ ការកេងប្រវ័ញ្ចក្នុងការរកស៊ីផ្លូវភេទ និងឧស្សាហកម្មអាសអាភាស។ (២សាំយូអែល ២២:២-៣)

7. ឱព្រះវរបិតាអើយ យើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលផ្តល់ជម្រកនៅទូទាំងប្រទេសហ្វាំងឡង់ សម្រាប់ម្តាយ និង កូនៗរបស់ពួកគេដែលជាជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ។ សូមនាំមកនូវការព្យាបាលដល់ជីវិតរបស់ពួកគេ។ (ទំនុកដំកើង ១៣៩:៥)

8. ករណីអំពើហិង្សាក្នុងគ្រួសារក្នុងប្រទេសបារាំងបានកើនឡើងទ្វេដងតាំងពីឆ្នាំ ២០១៦។ ឱព្រះអម្ចាស់អើយ សូមឲ្យបុរសៗអនុវត្តតាមព្រះបន្ទូលរបស់ព្រះអង្គក្នុងការស្រឡាញ់ភរិយារបស់ពួកគេហើយកុំធ្វើបាបនាងឡើយ។ (កូឡុស ៣:១៩)

9. ឱព្រះអម្ចាស់អើយ សូមព្រះអង្គព្យាបាល និង ការពារស្រ្តីនៅក្នុងប្រទេសឥណ្ឌូនេស៊ីដែលបានឆ្លងមេរោគអេដស៍ដោយមិនដឹងខ្លួនពីដៃគូរបស់ពួកគេ។ ជម្ងឺនេះភាគច្រើនបានចម្លងទៅកុមារដោយពួកគេមិនដឹងថាពួកគេជាអ្នកផ្ទុកមេរោគផង។ (ទំនុកដំកើង ៣០:២)

10. ឱព្រះជាម្ចាស់អើយ សូមព្រះអង្គជួយសង្គ្រោះស្រ្តីដែលរងការរំលោភបំពាននៅក្នុងប្រទេសជប៉ុន។ សូមឲ្យពួកគេបានជួបព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់ពួកគេ បានរៀនពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ហើយទទួលបានការព្យាបាលពីព្រះអង្គផងដែរ។ (ទំនុកដំកើង ១០៣:៦-៨)

11. ឱព្រះវរបិតាអើយ សូមព្រះអង្គលើកតម្កើងអ្នកដឹកនាំក្រុមជំនុំដើម្បីដោះស្រាយបញ្ហានៃការរួមភេទជាមួយសាច់ញាតិនៅក្នុងប្រទេស Liberia ។ សូមនាំមកនូវការព្យាបាល និងការគាំទ្រដល់ស្រ្តី និង ក្មេងស្រីដែលរងទុក្ខដោយស្ងប់ស្ងាត់ដោយសារតែការភ័យខ្លាច និងភាពអាម៉ាស់។ (អេសេគាល ២២:១១)

**TWR Korea 북방선교방송**
서울특별시 관악구 양녕로 15, 월드빌딩 6층
전화 (02)886-5671 / 이메일 hskim@twrk.or.kr

**12.** ឱព្រះអម្ចាស់អើយ
សូមការពារក្មេងស្រីនៅក្នុងប្រទេសម៉ាឡេស៊ីពីការអនុវត្តដ៏គ្រោះថ្នាក់នៃការ
កាត់ប្រដាប់ភេទស្ត្រី។ សូមព្យាបាលមុខរបួសរបស់ពួកគេ និង
សម្រាលទុក្ខវិញ្ញាណរបស់ពួកគេ។
សូមបន្ទន់ដួងចិត្តដល់អ្នកដឹកនាំឲ្យបង្កើតច្បាប់បញ្ចប់ទង្វើដ៏ឃោរ
ឃៅនេះឆាប់ៗផងដែរ។ (អេសាយ ១:១៧)

**13.** សូមឲ្យកូនក្រមុំវ័យកុមារ អ្នកជាប់ឃុំឃាំង និង
អ្នកដែលត្រូវគេបដិសេធនៅមជ្ឈិម បូព៌ាបានរកឃើញសេរីភាព និង
ដឹងពីតម្លៃពិតរបស់ពួកគេនៅក្នុងព្រះយេស៊ូវ។ (កាឡាទី ៥:១)

**14.** ស្ត្រីម៉ុងហ្គោលី ៤០% ជួបប្រទះការរំលោភបំពានផ្លូវអារម្មណ៍ និង
សេដ្ឋកិច្ច។ ឱព្រះវរបិតាអើយ សូមព្រះអង្គព្យាបាលពួកគេ និង
ផ្តល់កន្លែងសុវត្ថិភាពសម្រាប់ការការពារដល់ពួកគេផង។ (យេរេមា ២២:១៦)

**15.** ឱព្រះវរបិតាអើយ សូមឲ្យជនរងគ្រោះដោយការរំលោភសេពសន្ថវៈ
ការរួមភេទជាមួយសាច់ញាតិ អាពាហ៍ពិពាហ៍ដោយបង្ខំ ឬ
ការរំលោភបំពានផ្លូវកាយ និង
ផ្លូវចិត្តនៅក្នុងប្រទេសនីហ្សេរីយ៉ាបានរកឃើញសន្តិភាព និង
ការការពារនៅក្នុងព្រះអង្គ។
សូមឲ្យជនដែលជាអ្នករំលោភបំពានម្នាក់ៗត្រូវតែត្រូវបានកាត់ទោស។
(ទំនុកដំកើង ៣២:៧)

**16.**ស្ត្រីគ្រីស្ទបរិស័ទនៅអាហ្វ្រិកខាងជើងជាច្រើនប្រឈមមុខនឹងការបៀត
បៀន ការបដិសេធ និង ការរំលោភបំពាន។
សូមឲ្យព្រះវិញ្ញាណរបស់ព្រះអង្គប្រទានក្តីសង្ឃឹម
និងសមត្ថភាពដល់ស្ត្រីទាំងនេះឲ្យឈរយ៉ាងរឹងមាំនៅក្នុងព្រះយេស៊ូវ។
(កិច្ចការ ១៤:២២)

**17.**ស្ត្រីត្រូវបានចាត់ទុកជាកម្មសិទ្ធិក្រោមប្រពៃណីថ្លៃបណ្ណាការនៅក្នុងប្រ
ទេស Papua New Guinea ។ ឱព្រះអម្ចាស់អើយ
សូមព្រះអង្គព្យាបាលការឈឺចាប់របស់អ្នកដែលត្រូវបានរំលោភបំពាន និង
មានវិញ្ញាណបាក់បែកផង។ (យេរេមា ២២:៣)

**18.** ឱព្រះអម្ចាស់អើយ សូមទ្រង់ស្តាប់សំឡេងយំរបស់ក្មេងស្រី និង
ស្ត្រីនៅក្នុងប្រទេស ហ្វីលីពីន ខណៈដែលករណីរំលោភបានកើនឡើង
ហើយភាពបរិសុទ្ធរបស់ពួកគេត្រូវបានបាត់បង់។ សូមព្យាបាល ការពារ
និង ស្តារជីវិតដែលបាក់បែករបស់ពួកគេឡើងវិញ។ (យេរេមា ៣៣:៦)

**19.** ខណៈដែលអំពើហិង្សា និង
ការនិយាយស្អប់ខ្ពើមប្រឆាំងនឹងស្ត្រីកើនឡើងនៅក្នុងប្រទេសព័រទុយហ្គា
ល់ ឱព្រះជាម្ចាស់អើយ
សូមឲ្យច្បាប់ត្រូវបានបង្កើតឡើងសម្រាប់ការការពារស្ត្រី។
សូមឲ្យបុរសវ័យក្មេងក៏ត្រូវបានចិញ្ចឹមបីបាច់ឲ្យគោរពពួកគេដែរ។
(ម៉ាថាយ ២២:៣៩)

**20.** ឱព្រះវរបិតាអើយ
សូមប្រទានប្រាជ្ញាដល់មេដឹកនាំរដ្ឋាភិបាលអាហ្វ្រិកខាងត្បូងអំពីរបៀប
ដោះស្រាយបញ្ហានៃការរំលោភបំពាន និង ការរំលោភសេពសន្ថវៈលើកុមារ
និង ស្ត្រីដែលកំពុងកើនឡើង។ (១ធីម៉ូថេ ២:១-២)

**21.** រៀងរាល់បីទៅបួនថ្ងៃម្តង
មានអ្នកស្លាប់ដោយសារអំពើហិង្សាក្នុងពេលណាត់ជួបនៅ កូរ៉េខាងត្បូង។
ឱព្រះអម្ចាស់អើយ សូមជួយមនុស្សឲ្យទទួលស្គាល់ថា
អំពើហិង្សាក្នុងពេលណាត់ជួបរវាងគូស្នេហ៍វាមិនមែនជាស្នេហាទេ។
(អេភេសូរ ៤:៣១-៣២)

**22.** ឱព្រះអម្ចាស់អើយ ខណៈដែលស្ត្រីជាច្រើននៅប្រទេសតង់ហ្សានី
រងគ្រោះថ្នាក់ពីប្រពៃណីដូចជាការកាត់ប្រដាប់ភេទស្ត្រី និង ការវាយដំ
សូមនាំមកនូវការផ្លាស់ប្តូរវប្បធម៌ដើម្បីបញ្ឈប់ទង្វើទាំងនេះ។ (កាឡាទី ៥:១៤)

**23.** ឱព្រះជាម្ចាស់អើយ
សូមជួយជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនៅទីម័រ
ខាងកើតដែលខ្លាចមិនហ៊ាននិយាយចេញដោយសារការលំបាកផ្នែកសេដ្ឋ
កិច្ច និង ភាពអាម៉ាស់ក្នុងសង្គម។
សូមពន្លឺភ្លឺចូលទៅក្នុងទុក្ខលំបាកដ៏ស្ងប់ស្ងាត់របស់ពួកគេដែលកំពុងជាប់
អន្ទាក់។   (សុភាសិត ៣១:៨-៩)

**24.** ឱព្រះវរបិតាអើយ
សូមការពារស្ត្រីពីអំពើហិង្សាក្នុងគ្រួសារនៅប្រទេសអ៊ុយរូហ្គាយ
ដែលជាកន្លែងដែលមានពាក្យបណ្តឹងជាង ១០០ ករណីក្នុងមួយថ្ងៃ។
សូមនាំមកនូវការផ្លាស់ប្តូរចិត្តដល់ជនល្មើស។ (សុភាសិត ១៨:១០)

**25.** ឱព្រះអម្ចាស់អើយ
សូមសម្រាលទុក្ខដល់ស្ត្រីវៀតណាមដែលបានរងរបួសដោយចំណងផ្លូវអា
រម្មណ៍ និង វិញ្ញាណដ៏ស្ងប់ស្ងាត់។
សូមព្យាបាលដួងចិត្តដែលបាក់បែករបស់ពួកគេ
លើកស្ទួយវិញ្ញាណរបស់ពួកគេ
ហើយដោះលែងពួកគេនៅក្នុងសេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេររបស់ព្រះអង្គ។
(អេសាយ ៤០:២៩-៣១)

**26.** ឱព្រះវរបិតាអើយ
សូមនាំមកនូវការព្យាបាលដល់របួសផ្លូវចិត្តរបស់ស្ត្រី ២៨ នាក់នៅ
Zanzibar
ដែលបានឆ្លងកាត់កម្មវិធីបណ្តុះបណ្តាលព្យាបាលរបួសផ្លូវចិត្តថ្មីរបស់កម្មវិ
ធីស្ត្រីក្នុងក្តីសង្ឃឹម TWR។ (ទំនុកដំកើង ៣៤:១៨)

**27.** ឱព្រះអម្ចាស់អើយ
យើងសូមអធិស្ឋានសម្រាប់ការផ្លាស់ប្តូរវប្បធម៌នៅកម្ពុជា
ដែលស្ត្រីជាច្រើនត្រូវបានឪពុកម្តាយបង្ខំឲ្យរៀបការនៅវ័យក្មេង
ជាពិសេសនៅតាមជនបទ និង តំបន់ដាច់ស្រយាល។ (រ៉ូម ១៣:១០)

**28.**យើងសូមអធិស្ឋានសម្រាប់ស្ត្រីដែលប្រឈមមុខនឹងការរំលោភបំពាន
និង អ្នកដែលត្រូវបានបដិសេធដោយសារជំនឿរបស់ពួកគេនៅមជ្ឈិមបូព៌ា។
ឱព្រះជាម្ចាស់អើយ សូមធ្វើឲ្យវិញ្ញាណរបស់ពួកគេរស់ឡើងវិញ និង
សូមសម្រាលទុក្ខពួកគេផង។ (រ៉ូម ៨:៣១)

**29.** ឱព្រះវរបិតាអើយ យើងសូមអធិស្ឋានសម្រាប់ការផ្លាស់ប្តូរការអនុវត្ត
និង ជំនឿវប្បធម៌ដែលលើកទឹកចិត្តដល់ការរំលោភបំពាន និង
ការបដិសេធស្ត្រីនៅភាគខាងជើងប្រទេស នីហ្សេរីយ៉ា។ (កាឡាទី ៣:២៨)

**30.**២០%នៃស្ត្រីនឹងជួបប្រទះអំពើហិង្សាពីដៃគូជិតស្និទ្ធយ៉ាងហោចណា
ស់ម្តងក្នុងជីវិតរបស់ពួកគេ។
សូមឲ្យស្ត្រីបានរាយការណ៍ពីឧប្បត្តិហេតុទាំងនេះ។ ឱព្រះអម្ចាស់អើយ
សូមផ្លាស់ប្តូរចិត្តរបស់ជនល្មើសផងដែរ។ (ទំនុកដំកើង ៥១:១០)

**31.** ឱព្រះអម្ចាស់អើយ
របាយការណ៍អង្គការសហប្រជាជាតិថ្មីៗនេះបង្ហាញថា
ស្ត្រីម្នាក់ត្រូវបានសម្លាប់រៀងរាល់១០នាទីម្តងនៅទូទាំងពិភពលោក។
សូមព្រះអង្គការពារស្ត្រីដែលងាយនឹងរងគ្រោះ និង
ជួយដល់ពួកគេឲ្យដាក់ជំនឿរបស់ពួកគេនៅក្នុងព្រះអង្គផង។
(ទំនុកដំកើង ៤៦:១)

**후원안내**
**국민은행 851-01-0003-724 북방선교방송**
**최초 입금 후 사무실로 연락주시기 바랍니다.**